**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០២ សរ

មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត
លេខចុះ 205
ថ្ងៃទី 13 ខែ 9 ឆ្នាំ 2002

# សារាចរ
## ស្តីពី
## វិធានការទប់ស្កាត់សកម្មភាព
## លួចតម្លើងប្រព័ន្ធទូរស័ព្ទចេញចូលអន្តរជាតិ

កន្លងមកមានជនខិលខូចមួយចំនួន បានឃុបឃិតគ្នាជាមួយជនបរទេស ធ្វើការនាំចូលសំភារៈបរិក្ខារទូរគមនាគមន៍ និងតម្លើងប្រព័ន្ធទូរស័ព្ទធ្វើជាច្រកចេញចូលអន្តរជាតិ ដើម្បីបំពីរសេវាទូរគមនាគមន៍លួចលាក់ ។ សកម្មភាពល្មើសទាំងនេះ ធ្វើអោយប៉ះពាល់ដល់គុណភាពសេវាទូរស័ព្ទរបស់រដ្ឋផង និង ធ្វើអោយបាត់បង់នូវចំណូលថវិការដ្ឋយ៉ាងច្រើនផង ។ ដោយមានការចូលរួមយ៉ាងសកម្មពីកំលាំងនគរបាល កងរាជអាវុធហត្ថ និង ព្រះរាជអាជ្ញាអមតុលាការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ បានទប់ស្កាត់នូវបទល្មើសទាំងនេះ ហើយក៏ចាប់ជនល្មើសបានជាបន្តបន្ទាប់ ។ ប៉ុន្តែសកម្មភាពល្មើសនេះ នៅតែកើតមានជាបន្តបន្ទាប់ទាំងនៅទីក្រុង និង តាមបណ្តាខេត្តនានា ។

ចំពោះមុខដើម្បីទប់ស្កាត់នូវសកម្មភាពបទល្មើសខាងលើនេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំ និង មានវិធានការដូចតទៅ :

១-/ជនណាដែលប្រព្រឹត្តិអំពើល្មើសដូចបានរៀបរាប់ខាងលើនេះនឹងត្រូវផ្តន្ទាទោសជាទម្ងន់ ។

២-/សូមសាធារណជនជាអ្នកជិតខាង ឬ ជាម្ចាស់ផ្ទះជួល បើឃើញមានតម្លើងចានស្ពាយរណប ឬ ឧបករណ៍ទូរគមនាគមន៍ហួសពីការប្រើប្រាស់ក្នុងគ្រួសារ សូមធ្វើសេចក្តីរាយការណ៍មកក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ទូរស័ព្ទលេខ ០២៣ ៨២៦ ៨១០ ជាបន្ទាន់ ឬ ក៏ផ្តល់ព័ត៌មានមកក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

៣-/គ្រប់ក្រសួង ស្ថាប័ន និង អាជ្ញាធរដែនដីខេត្ត-ក្រុង គ្រប់ជាន់ថ្នាក់ ត្រូវចៀសវាងការរួមគំនិត ឬ ធ្វើអន្តរាគមន៍ការពារជនល្មើសក្នុងការតម្លើងប្រព័ន្ធទូរស័ព្ទច្រកចេញចូលអន្តរជាតិជាដាច់ខាត ។

៤./គ្រប់ក្រសួង ស្ថាប័ន និង អាជ្ញាធរដែនដីខេត្ត-ក្រុង គ្រប់ជាន់ថ្នាក់ ត្រូវសហការទប់ស្កាត់តាមសមត្ថកិច្ចរៀងៗខ្លួន ជាពិសេសមន្ត្រីមានសមត្ថកិច្ចតាមព្រំដែនត្រូវរឹតបន្តឹងអោយបានខ្ជាប់ខ្ជួនការនាំចូលបរិក្ខារទូរគមនាគមន៍ ដូចជាជាសផ្សាយរលក និង បរិក្ខារអេមអេចជាមួយផ្សេងៗទៀត បើគ្មានអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ជាមុន ។

៥./ក្នុងករណីមានបទល្មើសជាក់ស្តែង ទីតាំងពិតប្រាកដ អាជ្ញាធរដែនដី និង សមត្ថកិច្ចយុត្តិធម៌ ទទួលខុសត្រូវនៅទីនោះ ត្រូវសហការបន្ទាន់ជាមួយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដើម្បីចាប់ជនល្មើស និង វត្ថុតាងល្មើសឲ្យបញ្ជូនទៅតុលាការចាត់ការតាមផ្លូវច្បាប់ ។

៦./មន្ត្រីនៃក្រសួង ស្ថាប័នណាដែលចូលរួមដោយផ្ទាល់ ឬ ដោយប្រយោល បើស្រាវជ្រាវឃើញថាមានការពាក់ព័ន្ធនឹងបទល្មើសខាងលើត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និង រាជរដ្ឋាភិបាល ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមសាធារណជនជ្រាប ហើយគ្រប់ក្រសួង ស្ថាប័ន និង អាជ្ញាធរដែនដីខេត្ត-ក្រុង គ្រប់ជាន់ថ្នាក់ ត្រូវយកចិត្តទុកដាក់អនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៦

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់ខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ